13

19.02-11

ព្រះរាជក្រម

នស/រកម/០២១១/០០២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សម្ងានភូមិជាតិសាសនា រក្ខិតខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិង្ករាឆរមហាក្សត្រ
ខេមរាជនា សម្ងហោតាស កម្ពុជឯករាជ្យបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពហុភាគីអាស៊ាន ស្តីពីសេរីភាវូបនីយកម្មពេញលេញនៃសេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវអាកាស រួមទាំងពិធីសារចំនួន ២ និងកិច្ចព្រមព្រៀងពហុភាគីអាស៊ាន ស្តីពីសេវាកម្មដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាស រួមទាំងពិធីសារចំនួន ៦ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME du CAMBO

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពហុភាគីអាស៊ាន ស្តីពីសេរីភាវូបនីយកម្មពេញលេញនៃសេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវអាកាស រួមទាំងពិធីសារចំនួន ២ និងកិច្ចព្រមព្រៀងពហុភាគីអាស៊ានស្តីពីសេវាកម្មដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាស រួមទាំងពិធីសារចំនួន ៦

មាត្រា ១.-

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពហុភាគីអាស៊ានស្តីពីសេរីភាវូបនីយកម្មពេញលេញនៃសេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវអាកាស រួមទាំងពិធីសារចំនួន ២ និងកិច្ចព្រមព្រៀងពហុភាគីអាស៊ានស្តីពីសេវាកម្មដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាស រួមទាំងពិធីសារចំនួន ៦ ដែលបានចុះហត្ថលេខានៅទីក្រុងម៉ានីឡា ប្រទេសហ្វីលីពីន នាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀង និងពិធីសារនេះ។

មាត្រា ៣.-

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១១

ព្រះហស្តលេខា និងព្រះរាជលញ្ឆកអរ

នរោត្តម សីហមុនី

៣រល. ១១០២. ២៣៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ផ្ទៃលេខាធិការអាកាសចរស៊ីវិល

ហត្ថលេខា

ម៉ៅ ហាវណ្ណាល់

លេខ ១៧៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១
អគ្គលេខាធិការរដ្ឋសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល

កិច្ចព្រមព្រៀងពហុភាគីអាស៊ាន
ស្តីពីសេរីភាវូបនីយកម្មពេញលេញ
នៃសេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវអាកាស
រួមទាំងពិធីសារចំនួន ២

និង

កិច្ចព្រមព្រៀងពហុភាគីអាស៊ាន
ស្តីពីសេវាកម្មដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាស
រួមទាំងពិធីសារចំនួន ៦

កិច្ចព្រមព្រៀងពហុភាគីអាស៊ាន
ស្តីពីសេរីភាវូបនីយកម្មពាណិជ្ជកម្ម នៃសេវាកម្មដឹកជញ្ជូនផ្លូវអាកាស

រដ្ឋាភិបាលនៃប្រទេសប្រ៊ុយណេដារូសាឡាម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសឹង្ហបូរី ព្រះរាជាណាចក្រថៃឡង់ដ៍ និង សាធារណរដ្ឋសង្គមនិយមវៀតណាម ដែលជារដ្ឋសមាជិកនៃសមាគមន៍ប្រជាជាតិ អាស៊ីអាគ្នេយ៍ហៅ (អាស៊ាន) (ដែលចាប់ពីពេលនេះតទៅមានឈ្មោះក្នុងលក្ខណៈរួមថាជា "បណ្តាភាគីចុះកិច្ចព្រមព្រៀង" ឬ ក្នុងលក្ខណៈជាបុគ្គលថា "ភាគីចុះកិច្ចព្រមព្រៀង") ។

ដោយរំលឹកដល់សេចក្តីប្រកាសនៃការព្រមព្រៀងលើកទី ២ របស់អាស៊ាន (ការព្រមព្រៀងលើកទី ២ នៅបាលី) ដែលបានចេញនៅបាលី ប្រទេសឥណ្ឌូនេស៊ី កាលពីថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៣ អនុលោមទៅតាមអ្វី ដែលអាស៊ានបានសន្យាអោយមានសមាហរណកម្មសេដ្ឋកិច្ចផ្ទៃក្នុងរបស់ខ្លួន អោយស៊ីជម្រៅ និងទូលំទូលាយ ហើយពាក់ព័ន្ធជាមួយសេដ្ឋកិច្ចពិភពលោក ដើម្បីសម្រេចបានសហគមន៍សេដ្ឋកិច្ចអាស៊ានមួយ ។

ដោយបញ្ជាក់របៀបវារៈគោលនយោបាយ សំរាប់ការអនុវត្តន៍ជឿនលឿន នៃសេរីភាវូបនីយកម្មពេញលេញ និង សមាហរណកម្មនៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសនៅក្នុងតំបន់អាស៊ាន ដូចដែលបាននិយាយនៅក្នុងផែនការសកម្មភាពសំរាប់សមាហរណកម្មដឹកជញ្ជូនតាមផ្លូវអាកាសនៅក្នុងតំបន់អាស៊ាន និង សេរីភាវូបនីយកម្ម ដែលបានអនុម័តនៅកិច្ចប្រជុំរដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ានលើកទី ១០ កាលពីថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៤ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

ដោយរំលឹកកម្មវិធីសកម្មភាពវៀងចន្ទន៍ ដែលបានអនុម័តនៅកិច្ចប្រជុំកំពូលអាស៊ានលើកទី ១០ កាលពី ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤ នៅទីក្រុងវៀងចន្ទន៍ ប្រទេសឡាវ ដែលហៅថា សំរាប់ពង្រឹងការរៀបចំបើកចំហរជើងមេឃ និង សេរីភាវូបនីយកម្មជឿនលឿននៅក្នុងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ជាពិសេសសេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវអាកាស ។

ដោយរំលឹកផងដែរថា ការសម្រេចនៃកិច្ចប្រជុំរដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ានលើកទី ១០ នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ដើម្បីអនុម័តផែនទីបង្ហាញផ្លូវសំរាប់សមាហរណកម្មនៃវិស័យដឹកជញ្ជូនតាមផ្លូវអាកាស និង ផែនការសកម្មភាពសំរាប់សមាហរណកម្មដឹកជញ្ជូនតាមផ្លូវអាកាសអាស៊ាន និង សេរីភាវូបនីយកម្ម ឆ្នាំ ២០០៥ ដល់ ឆ្នាំ ២០១៥ ដែលផ្តល់សកម្មភាពយុទ្ធសាស្ត្រ ដើម្បីធ្វើសេរីភាវូបនីយកម្មសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសនៅក្នុងតំបន់អាស៊ាន និង ដើម្បីជំរុញអោយបរិយាកាសវៀងភាពមួយនៅក្នុងតំបន់អាស៊ាន ។

ការដែលបានសន្យា ដើម្បីថែរក្សា អភិវឌ្ឍន៍ និង ទំនាក់ទំនងមិត្តភាពយ៉ាងជិតស្និទ្ធរឹងមាំបន្ថែមទៀត និងសហប្រតិបត្តិការ រវាង ក្នុងចំណោមប្រទេសរបស់ពួកគេ។

ដោយទទួលស្គាល់ថា សេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវអាកាសអន្តរជាតិ ដែលមានសមត្ថភាព និង មានការប្រកួតប្រជែង គឺមានសារៈសំខាន់ ដើម្បីអភិវឌ្ឍន៍ពាណិជ្ជកម្ម ផលប្រយោជន៍របស់អ្នកប្រើប្រាស់ និងជំរុញការរីកលូតលាស់នៃសេដ្ឋកិច្ច។

ដោយមានគោលបំណង ដើម្បីធានាកំរិតខ្ពស់បំផុតនៃសុវត្ថិភាព និង សន្តិសុខក្នុងការដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ និង បញ្ជាក់បន្ថែមទាក់ទិនអំពីសកម្មភាព ឬ ការគំរាមកំហែងប្រឆាំងសន្តិសុខអាកាសយាន ដែលធ្វើអោយអន្តរាយសុវត្ថិភាពទ្រព្យសម្បត្តិ មានឥទ្ធិពលដោយផ្ទុយពីការប្រតិបត្តិការដឹកជញ្ជូនតាមផ្លូវអាកាស និង ការមានទំនុកចិត្តដល់សាធារណៈជននៅក្នុងសុវត្ថិភាពអាកាសចរស៊ីវិល។

ដោយមានគោលបំណង ដើម្បីជួយសំរួល និង បង្កើនសេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវអាកាស និង សកម្មភាពដែលបានពាក់ព័ន្ធ ដើម្បីអនុវត្តការសំរួលការដឹកជញ្ជូនផ្សេងៗ និង កិច្ចខិតខំប្រឹងប្រែងទៅលើសេរីភាវូបនីយកម្មនៅក្នុងតំបន់អាស៊ាន។

ដោយមានគោលបំណង ដើម្បីដកចេញការរឹតបន្តឹង ឈរលើមូលដ្ឋានជាជំហានៗ ដើម្បីនឹងសម្រេចគោលបំណងចំពោះភាពប្រែប្រួលនៃកំណើន និង ចំណុះដឹកជញ្ជូន ក្នុងប្រតិបត្តិការនៃសេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវអាកាសអាស៊ាន ដើម្បីស្ថាបនាទីផ្សារអាកាសចរស៊ីវិលឯកភាពរួមរបស់អាស៊ាននៅឆ្នាំ ២០១៥។

ជាផ្នែករបស់អនុសញ្ញា ស្តីពីអាកាសចរស៊ីវិលអន្តរជាតិ ដែលបានបើកអោយចុះហត្ថលេខានៅ ស៊ីកាហ្គោ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៤៤ និង មានគោលបំណងដើម្បីប្រកាន់ភ្ជាប់គោលការណ៍ និង ខ្លឹមសារ នៃអនុសញ្ញា។

ដោយមានគោលបំណង ដើម្បីឈានដល់ការសំរេចអោយបានកិច្ចព្រមព្រៀងពហុភាគី ស្តីពី សេរីភាវូបនីយកម្មពេញលេញនៃសេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវអាកាស។

បានឯកភាពគ្នាដូចតទៅ៖

មាត្រា ១
និយមន័យ

សំរាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះប៉ុណ្ណោះ បើមិនដូច្នោះ អត្ថបទទាំងមូលតម្រូវអោយ ៖

១. ពាក្យ "អនុសញ្ញា" មានន័យថា អនុសញ្ញា ស្តីពីអាកាសចរស៊ីវិលអន្តរជាតិ ដែលបានបើកអោយចុះហត្ថលេខានៅ ស៊ីកាហ្គោ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៤៤ និង រួមមាន (i) ការធ្វើវិសោធនកម្មណាមួយ ដែលត្រូវបានចូលជាធរមាន ស្ថិតនៅក្រោមមាត្រា ៩៤ (ក) នៃអនុសញ្ញា និង ផ្តល់សច្ចាប័ន ដោយភាគីចុះកិច្ចព្រមព្រៀងទាំងអស់ទៅនឹងកិច្ចព្រមព្រៀងនេះ និង (ii) ឧបសម្ព័ន្ធណាមួយ ឬ វិសោធនកម្មណាមួយដែលមានហើយត្រូវបានអនុម័តក្រោមមាត្រា ៩០ នៃអនុសញ្ញានេះ ដែលឧបសម្ព័ន្ធ ឬ វិសោធនកម្មនេះ មានប្រសិទ្ធិភាពទៅលើភាគីចុះកិច្ចព្រមព្រៀងទាំងអស់នៃកិច្ចព្រមព្រៀងនេះ។

២. ពាក្យ "អាជ្ញាធរអាកាសចរ" មានន័យថា រដ្ឋមន្ត្រីទទួលបន្ទុកអាកាសចរស៊ីវិល ឬ បុគ្គល ឬ អង្គភាពណាមួយ ដែលត្រូវបានអនុញ្ញាតអោយបំពេញតួនាទីចំពោះភារកិច្ចរបស់ខ្លួន ឬ តួនាទីប្រហាក់ប្រហែលគ្នា។

៣. ពាក្យ "ក្រុមហ៊ុនអាកាសចរដែលបានចាត់តាំង" មានន័យថា ក្រុមហ៊ុនអាកាសចរមួយ ដែលត្រូវបានចាត់តាំង និង អនុញ្ញាតស្របតាមមាត្រា ៣ (ការចាត់តាំង និង ការអនុញ្ញាតក្រុមហ៊ុនអាកាសចរ) នៃកិច្ចព្រមព្រៀងនេះ។

៤. ពាក្យ "បូរណភាពដែនដី" មានន័យថា ដែនដីគោក ដែនទឹក ដែនសមុទ្រ ទីប្រជុំកោះ ផ្ទៃសមុទ្រ និង ធនធានក្រោមដី និង ផ្ទៃអាកាសខាងលើ។

៥. ពាក្យ "សេវាកម្មផ្លូវអាកាស" "សេវាកម្មផ្លូវអាកាសអន្តរជាតិ" និង "ក្រុមហ៊ុនអាកាសចរ" មានន័យដោយឡែក។ពីគ្នាដែលមានចែងនៅក្នុងមាត្រា ៩៦ នៃអនុសញ្ញានេះ។

៦. ពាក្យ "សេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវអាកាសអន្តរជាតិ" មានន័យថា ការដឹកជញ្ជូនទំនិញតាមផ្លូវអាកាសទាំងអស់ ដែលឆ្លងកាត់ដែនអាកាសនៅលើទឹកដីរដ្ឋជាសមាជិកអាស៊ាន លើសពីមួយ។

៧. ពាក្យ "តម្លៃ" មានន័យថា តម្លៃ អត្រាតម្លៃ ឬ ថ្លៃឈ្នួលណាមួយ សំរាប់ការដឹកជញ្ជូនទំនិញ (លើកលែងកញ្ចប់ប្រៃសណីយ៍) នៅក្នុងការដឹកជញ្ជូនតាមផ្លូវអាកាស ដែលកំណត់តម្លៃដោយក្រុមហ៊ុនអាកាសចរ រួមទាំង ភ្នាក់ងាររបស់ខ្លួន និង លក្ខខ័ណ្ឌដែលគ្រប់គ្រងទៅលើតម្លៃ អត្រាតម្លៃ ឬ ថ្លៃឈ្នួលនេះ។

បកប្រែជាផ្លូវការ

៨. ពាក្យ "សេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវអាកាស" មានន័យថា សេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវអាកាសក្នុងកម្មវិធី ដែលអនុវត្តចំពោះការដឹកជញ្ជូនទំនិញ ឬក៏កញ្ចប់ប្រៃសណីយ៍ ដើម្បីយកផលកម្រៃ ឬ ជួលនៅលើផ្លូវដែលបានកំណត់។

៩. ពាក្យ "ការឈប់សំចតមិនធ្វើពាណិជ្ជកម្ម" មានន័យថា ការចុះចតក្នុងគោលបំណងណាមួយក្រៅពីលើកដាក់ ឬ ផ្ទុកទំនិញ ឬក៏កញ្ចប់ប្រៃសណីយ៍ចុះក្នុងលក្ខណៈសេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវអាកាសអន្តរជាតិ។

១០. ពាក្យ "តម្លៃប្រើប្រាស់" មានន័យថា តម្លៃដែលកំណត់យកដោយអាជ្ញាធរមានសមត្ថកិច្ចលើក្រុមហ៊ុនអាកាសចរ ឬ ត្រូវបានអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ច ដែលនឹងត្រូវកំណត់តម្លៃទៅលើការផ្តល់សេវាកម្ម សំភារៈអាកាសយានដ្ឋាន ឬ ឧបករណ៍ ឬ ឧបករណ៍បញ្ជាចរាចរដែនអាកាស រួមទាំងសេវាកម្មពាក់ព័ន្ធនិង ឧបករណ៍បំរើសេវាកម្មអាកាសយាន ក្រុមអាកាសយានិកនិងទំនិញ។

១១. ពាក្យ "កិច្ចព្រមព្រៀង" មានន័យថា កិច្ចព្រមព្រៀងនេះ និង ពិធីសារកំពុងអនុវត្ត នៃកិច្ចព្រមព្រៀងនេះ និង វិសោធនកម្មណាមួយដែលមាន។

១២. ពាក្យ "កន្លែងដាក់លិកិច្ចព្រមព្រៀង" មានន័យថា អគ្គលេខាធិការដ្ឋានអាស៊ាន។

១៣. សេចក្តីយោងទាំងអស់ចំពោះពាក្យឯកវចនៈត្រូវរួមបញ្ចូលទាំងពហុវចនៈ ហើយសេចក្តីយោងទាំងអស់ចំពោះពាក្យពហុវចនៈត្រូវបញ្ចូលទាំងឯកវចនៈ។

មាត្រា ២
ការផ្តល់សិទ្ធិ

១. ភាគីចុះកិច្ចព្រមព្រៀងនីមួយៗត្រូវផ្តល់សិទ្ធិទៅអោយភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀត សំរាប់បំរើសេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវអាកាសអន្តរជាតិដោយក្រុមហ៊ុនអាកាសចរដែលបានចាត់តាំងរបស់ភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀតៈ

ក. សិទ្ធិហោះហើរឆ្លងកាត់ទឹកដីរបស់ខ្លួនដោយមិនចុះចត។

ខ. សិទ្ធិធ្វើការឈប់សំចតនៅក្នុងទឹកដីរបស់ខ្លួនដោយមិនធ្វើពាណិជ្ជកម្ម។

គ. សិទ្ធិដែលមានកំណត់នៅក្នុងកិច្ចព្រមព្រៀងនេះ រួមទាំងសិទ្ធិដែលមានបញ្ជាក់នៅក្នុងពិធីសារកំពុងអនុវត្ត ១ និង ២ នៃកិច្ចព្រមព្រៀងនេះ។

២. ទោះបីកិច្ចព្រមព្រៀងនេះ មិនមានចែងអំពីការផ្តល់ទៅអោយក្រុមហ៊ុនអាកាសចរនេះ នៃភាគីចុះកិច្ចព្រមព្រៀងមួយនូវសិទ្ធិផ្ទុកទំនិញនៅក្នុងទឹកដីនៃភាគីចុះកិច្ចព្រមព្រៀងដទៃទៀត នូវទំនិញ កញ្ចប់ប្រៃសណីយ៍ ដែលគេដឹកជញ្ជូន ដើម្បីយកផលកម្រៃ ហើយដឹកជញ្ជូនឆ្ពោះទៅកាន់ចំណុចដទៃផ្សេងទៀតនៅក្នុងទឹកដីនៃភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀត។

មាត្រា ៣

ការចាត់តាំង និង ការអនុញ្ញាតក្រុមហ៊ុនអាកាសចរ

១. ភាគីចុះកិច្ចព្រមព្រៀងនីមួយៗមានសិទ្ធិចាត់តាំងក្រុមហ៊ុនអាកាសចរ ដែលខ្លួនចង់បង្កើត ក្នុងគោលបំណងធ្វើសេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវអាកាសអន្តរជាតិស្របតាមកិច្ចព្រមព្រៀងនេះ និង មានសិទ្ធិដកហូត ឬ កែប្រែការចាត់តាំងនេះ។ ការចាត់តាំងនេះត្រូវបញ្ជូនតាមរយៈកំណត់ទូតដោយសរសេរជាលាយលក្ខណ៍អក្សរទៅកន្លែងដំកល់កិច្ចព្រមព្រៀង ហើយត្រូវជូនដំណឹងទៅភាគីចុះកិច្ចព្រមព្រៀងទាំងអស់ជាបន្តបន្ទាប់។

២. នៅពេលទទួលបានការចាត់តាំង និង ពាក្យស្នើសុំពីក្រុមហ៊ុនអាកាសចរដែលបានចាត់តាំងក្នុងលក្ខណៈដែលមានបញ្ជាក់ ដើម្បីសុំការអនុញ្ញាតធ្វើប្រតិបត្តិការ និង ការអនុញ្ញាតបច្ចេកទេស ភាគីចុះកិច្ចព្រមព្រៀងនីមួយៗត្រូវផ្តល់ការអនុញ្ញាតសមស្រប ដោយពុំអោយមានការយឺតយ៉ាវ លុះត្រាតែ៖

ក. (i) លុះត្រាតែ ម្ចាស់កម្មសិទ្ធិត្រឹមត្រូវ និង ការគ្រប់គ្រងដ៏មានប្រសិទ្ធិភាពនៃក្រុមហ៊ុនអាកាសចរនោះ ជាកម្មសិទ្ធិភាគីចុះកិច្ចព្រមព្រៀងដែលចាត់តាំងក្រុមហ៊ុនអាកាសចរនោះ បុគ្គលដែលមានសញ្ជាតិនៃភាគីចុះកិច្ចព្រមព្រៀងនោះ ឬ រួមទាំងពីរ ឬ

(ii) យោងលើការទទួលយករបស់ភាគីចុះកិច្ចព្រមព្រៀងមួយ ដែលទទួលពាក្យស្នើសុំនេះ ក្រុមហ៊ុនអាកាសចរ ដែលបានចាត់តាំងមានសិទ្ធិធ្វើអាជីវកម្មស្របច្បាប់ ហើយមានស្នាក់ការពាណិជ្ជកម្មធំនៅក្នុងទឹកដីនៃភាគីចុះកិច្ចព្រមព្រៀង ក្រុមហ៊ុនអាកាសចរដែលបានចាត់តាំងនោះ នៅតែជាម្ចាស់កម្មសិទ្ធិត្រឹមត្រូវ និង ត្រូវបានត្រួតពិនិត្យប្រកបដោយប្រសិទ្ធិភាព ដោយប្រទេសសមាជិកអាស៊ានមួយ ឬ ច្រើន ឬក៏បុគ្គលរបស់ខ្លួន និង ភាគីចុះកិច្ចព្រម

(iii) ក្រុមហ៊ុនអាកាសចរដែលបានចាត់តាំង ទទួលបានការអនុញ្ញាតធ្វើអាជីវកម្មស្របច្បាប់ និង មានស្ថាក់ការពាណិជ្ជកម្មធំរបស់ខ្លួនទៅក្នុងទឹកដីនៃភាគីចុះកិច្ចព្រមព្រៀងចាត់តាំង ដែលភាគីចុះកិច្ចព្រមព្រៀងចាត់តាំងក្រុមហ៊ុនអាកាសចរនេះ មានការគ្រប់គ្រង និងគាំពារផ្នែកច្បាប់យ៉ាងមានប្រសិទ្ធិភាពទៅលើក្រុមហ៊ុនអាកាសចរនេះ លុះត្រាតែកិច្ចព្រមព្រៀងនេះ មិនមានន័យស្នើក្នុងការអនុញ្ញាតក្រុមហ៊ុនអាកាសចរ ឬ ក្រុមហ៊ុនអាកាសចរបន្ទាប់បន្សំរបស់ខ្លួន របស់រដ្ឋមិនមែនជាសមាជិកអាស៊ានទទួលបានសិទ្ធិធ្វើចរាចរដោយផ្ទាល់ ឬ ប្រយោល មិនអោយដូចក្រុមហ៊ុនអាកាសចរខ្លួនឡើយ ។

ខ. ក្រុមហ៊ុនអាកាសចរ ដែលមានការចាត់តាំង មានសមត្ថភាពក្នុងការបំពេញលក្ខខ័ណ្ឌផ្សេងៗ ដែលមានចែងនៅក្នុងច្បាប់ បទបញ្ជត្តិ និង លក្ខន្តិកៈនានា កំពុងអនុវត្តទៅលើសេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវអាកាសអន្តរជាតិ របស់ភាគីចុះកិច្ចព្រមព្រៀង ដែលផ្អែកទៅលើពាក្យស្នើសុំមានបញ្ជាក់នោះ និង

គ. ភាគីចុះកិច្ចព្រមព្រៀង ដែលចាត់តាំងក្រុមហ៊ុនអាកាសចរ ត្រូវស្របទៅតាមខ្លឹមសារដែលមានចែងនៅក្នុងមាត្រា ៥ (សុវត្ថិភាព) និង មាត្រា ៦ (សន្តិសុខអាកាសចរ) នៃកិច្ចព្រមព្រៀងនេះ ។

៣. ភាគីចុះកិច្ចព្រមព្រៀង ដែលផ្តល់សិទ្ធិអនុញ្ញាតធ្វើប្រតិបត្តិការ ស្របតាមកថាខ័ណ្ឌ ២ នៃមាត្រានេះ ត្រូវជូនដំណឹងអំពីការផ្តល់នេះទៅកន្លែងដំកល់ទុកឯកសារ ដែលត្រូវជូនដំណឹងបន្តទៅភាគីចុះកិច្ចព្រមព្រៀងទាំងអស់ ។

មាត្រា ៤

ការដកហូត ការរំលាយ ការផ្អាកបណ្តោះអាសន្ន និង ការដាក់កំរិតអនុញ្ញាត

១. ភាគីចុះកិច្ចព្រមព្រៀងនីមួយៗមានសិទ្ធិដកហូត រំលាយ ផ្អាក ដាក់លក្ខខ័ណ្ឌ ឬ ដាក់កំរិតទៅលើច្បាប់អនុញ្ញាតប្រតិបត្តិការ ឬ លិខិតអនុញ្ញាតបច្ចេកទេស ដែលមានចែងនៅក្នុងមាត្រា ៣ (ការចាត់តាំង និងការអនុញ្ញាត នៃក្រុមហ៊ុនអាកាសចរ) នៃកិច្ចព្រមព្រៀងនេះ ចំពោះក្រុមហ៊ុនអាកាសចរ ដែលត្រូវបានចាត់តាំងដោយភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀត ជាបណ្តោះអាសន្ន ឬ អចិន្ត្រៃយ៍ ក្នុងករណីដែល ៖

ក. ក្រុមហ៊ុនអាកាសចរខកខានមិនបានបង្ហាញថា ខ្លួនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្រោម

ខ. ក្រុមហ៊ុនអាកាសចរមិនបានបំពេញតាមច្បាប់ បទបញ្ជា និង បទបញ្ជា ដែលមានចែងក្នុងមាត្រា ១៥(ការអនុវត្តន៍ច្បាប់) នៃកិច្ចព្រមព្រៀងនេះ ឬ

គ. ភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀត មិនបានថែរក្សា និង គ្រប់គ្រងចំពោះស្តង់ដារ ដូចដែលមានចែងទៅក្នុងមាត្រា ៥(សុវត្ថិភាព) នៃកិច្ចព្រមព្រៀងនេះ ។

២. ប្រសិនបើមានវិធានការមួយដាបន្ទាន់ ដើម្បីទប់ស្កាត់ចំពោះការអនុវត្តន៍មិនស្របច្បាប់បន្តទៀត ចំពោះកថាខ័ណ្ឌ ១ (ខ) ឬ ១ (គ) នៃមាត្រានេះ សិទ្ធិដែលកំណត់ឡើងដោយមាត្រានេះ ត្រូវអនុវត្តទៅលុះត្រាតែ ក្រោយមានការពិគ្រោះយោបល់ជាមួយភាគីចុះកិច្ចព្រមព្រៀង ដែលចាត់តាំងក្រុមហ៊ុនអាកាសចរស្របតាមខ្លឹមសារដែលមានចែងនៅក្នុងមាត្រា ១៧(ការពិគ្រោះយោបល់ និង ការធ្វើវិសោធនកម្ម) ។

៣. ភាគីចុះកិច្ចព្រមព្រៀង ដែលបានអនុវត្តសិទ្ធិរបស់ខ្លួន មានសិទ្ធិដកហូត រំលាយ ផ្អាក ដាក់លក្ខខ័ណ្ឌ ឬ ដាក់កំរិត ទៅលើច្បាប់អនុញ្ញាតធ្វើប្រតិបត្តិការ ឬ លិខិតអនុញ្ញាតបច្ចេកទេស នៃក្រុមហ៊ុនអាកាសចរមួយ ឬ ច្រើន ស្របតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ ត្រូវជូនដំណឹង ទៅទីស្នាក់ការដឹកជញ្ជូនតាមអាកាសចរ បើយម្តកទទួលដឹកលកិច្ចព្រមព្រៀងត្រូវជូនដំណឹងភ្លាមទៅភាគីចុះកិច្ចព្រមព្រៀងទាំងអស់ ។

៤. មាត្រានេះ មិនកំណត់សិទ្ធិនៃភាគីចុះកិច្ចព្រមព្រៀងណាមួយ ដើម្បីដកហូត រំលាយ ផ្អាក ដាក់លក្ខខ័ណ្ឌ ឬ ដាក់កំរិតទៅលើច្បាប់អនុញ្ញាតប្រតិបត្តិការ ឬ លិខិតអនុញ្ញាតបច្ចេកទេសរបស់ក្រុមហ៊ុនអាកាសចរមួយ ឬ ច្រើន នៃភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀតស្របតាមខ្លឹមសារនៃមាត្រា ៦(សន្តិសុខអាកាសចរ) ។

មាត្រា ៩
សុវត្ថិភាព

១. ភាគីចុះកិច្ចព្រមព្រៀងនីមួយៗត្រូវទទួលស្គាល់សុពលភាព ចំពោះការធ្វើប្រតិបត្តិការសេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវអាកាស ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ វិញ្ញាបនបត្រសុវត្ថិភាពហោះបើរ វិញ្ញាបនបត្រពេញសមត្ថភាព និង អាជ្ញាប័ណ្ណក្រុមហ៊ុនអាកាសចរដែលបានចាត់តាំង ត្រូវបានចេញ ឬ ប្រគល់អោយដោយភាគីចុះកិច្ចព្រមព្រៀង ដែលចាត់តាំងក្រុមហ៊ុនអាកាសចរនោះ ហើយនៅមានជាធរមាន លុះត្រាតែតម្រូវអោយមានវិញ្ញាបនបត្រ ឬ អាជ្ញាប័ណ្ណ គឺយ៉ាងហោចណាស់អោយស្មើស្តង់ដាអប្បបរិមា ដែលត្រូវបានកំណត់ស្របតាម *អនុសញ្ញា*។ ភាគីចុះកិច្ចព្រមព្រៀងនីមួយៗ ត្រូវរក្សាសិទ្ធិបដិសេធ ដើម្បីទទួលស្គាល់ថា មានសុពលភាព ចំពោះគោលបំណងនៃការហោះបើរលើទឹកដីរបស់ខ្លួន នូវវិញ្ញាបនបត្រ

ពេញសមត្ថភាព និង អាជ្ញាប័ណ្ណ ដែលបានប្រគល់ ឬ ចេញអោយ ចំពោះបុគ្គលសញ្ជាតិផ្ទាល់របស់ខ្លួន ដោយ ភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀត ។

២. ភាគីចុះកិច្ចព្រមព្រៀងនីមួយៗអាចស្នើសុំពិគ្រោះយោបល់ ទាក់ទងទៅនឹងស្តង់ដាសុវត្ថិភាព និង ស្តង់ដាសន្តិសុខ ដែលគ្រប់គ្រងដោយភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀត ពាក់ព័ន្ធនឹងឧបករណ៍អាកាសចរ ក្រុមអាកាសយានិក អាកាសយាន និង ប្រតិបត្តិការរបស់ក្រុមហ៊ុនអាកាសចរ ដែលបានចាត់តាំងនៃភាគី ចុះកិច្ចព្រមព្រៀងផ្សេងទៀត។ ក្រោយពីកិច្ចពិគ្រោះយោបល់នេះ ប្រសិនបើភាគីចុះកិច្ចព្រមព្រៀងស្នើសុំ នោះ យល់ឃើញថា ភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀតមិនបានចាត់ចែង និង គ្រប់គ្រងស្តង់ដាសន្តិសុខ និង សុវត្ថិភាព និង លក្ខខ័ណ្ឌ នៅក្នុងផ្នែកទាំងនេះ ដ៏មានប្រសិទ្ធិភាពយ៉ាងហោចណាស់អោយស្មើស្តង់ដា អប្បបរិមា ដែលមានចែងស្របតាមអនុសញ្ញា ភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀតត្រូវបានជូនដំណឹងអំពីការ រកឃើញនេះ និង វិធានការដែលគិតថាចាំបាច់ ដើម្បីអនុវត្តអោយស្របស្តង់ដាអប្បបរិមាទាំងនេះ និង ភាគី ចុះកិច្ចព្រមព្រៀងផ្សេងទៀតនេះ ត្រូវចាត់វិធានការរួមអោយបានត្រឹមត្រូវ។ ភាគីចុះកិច្ចព្រមព្រៀង នីមួយៗរក្សាសិទ្ធិ ដើម្បីដកហូត រំលាយ ផ្អាក ដាក់លក្ខខ័ណ្ឌ ឬ ដាក់កំរិតទៅលើច្បាប់អនុញ្ញាតប្រតិបត្តិការ ឬ លិខិតអនុញ្ញាតបច្ចេកទេស របស់ក្រុមហ៊ុនអាកាសចរមួយ ឬ ច្រើន ដែលត្រូវបានចាត់តាំងដោយភាគីចុះកិច្ច ព្រមព្រៀងផ្សេងទៀត ក្នុងករណីដែលភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀត មិនបានចាត់វិធានការរួមត្រឹមត្រូវ ក្នុងរយៈពេលសមស្របមួយ ។

មាត្រា ៦
សន្តិសុខអាកាសចរ

១. ស្របតាមសិទ្ធិ និង កាតព្វកិច្ចរបស់ខ្លួនក្រោមច្បាប់អន្តរជាតិ ភាគីចុះកិច្ចព្រមព្រៀងត្រូវធានា អះអាងចំពោះកាតព្វកិច្ចរបស់ខ្លួនទៅវិញទៅមក ដើម្បីការពារសន្តិសុខអាកាសចរស៊ីវិលប្រឆាំងទៅនឹងអំពើ ជ្រៀតជ្រែកខុសច្បាប់ ដែលបង្កើតបានជាផ្នែកមួយដ៏សំខាន់នៃកិច្ចព្រមព្រៀងនេះ។ ដោយពុំមានកំរិតភាព ទូទៅនៃសិទ្ធិ និង កាតព្វកិច្ច របស់ខ្លួនក្រោមច្បាប់អន្តរជាតិ ភាគីចុះកិច្ចព្រមព្រៀងត្រូវអនុវត្តអោយស្រប តាមខ្លឹមសារនៃអនុសញ្ញាស្តីពីបទល្មើស និង អំពើល្មើសផ្សេងៗទៀត ដែលប្រព្រឹត្តនៅលើអាកាសយាន ចុះហត្ថលេខានៅទីក្រុងតូក្យូថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៦៣ អនុសញ្ញា ស្តីពីការបង្ក្រាបការចាប់រឹបអូសយក អាកាសយានខុសច្បាប់ ចុះហត្ថលេខានៅទីក្រុងហាក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៧០ និង អនុសញ្ញា ស្តីពី ការបង្ក្រាបអំពើខុសច្បាប់ប្រឆាំងនឹងសុវត្ថិភាពអាកាសចរស៊ីវិល ចុះហត្ថលេខានៅទីក្រុងម៉ុងត្រេអាល់ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៧១ ព្រមទាំងអនុសញ្ញា ឬ ពិធីសារណាមួយផ្សេងទៀត ដែលពាក់ព័ន្ធនឹង

២. ភាគីចុះកិច្ចព្រមព្រៀងនីមួយៗត្រូវផ្តល់ជំនួយចាំបាច់ទាំងអស់ទៅវិញទៅមកតាមការស្នើសុំ ពីភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀត ដើម្បីទប់ស្កាត់អំពើចាប់យកអាកាសយានស៊ីវិលខុសច្បាប់ និង អំពើខុសច្បាប់ផ្សេងៗទៀត ប្រឆាំងនឹងសុវត្ថិភាពអាកាសយាន អាកាសយានិក និង អាកាសយានដ្ឋាន និង ឧបករណ៍បញ្ជាចរាចរដែនអាកាស និង ដើម្បីទប់ទល់អំពើគំរាមកំហែងណាមួយផ្សេងៗទៀត ចំពោះសន្តិសុខអាកាសចរស៊ីវិល ។

៣. ក្នុងទំនាក់ទំនងទៅវិញទៅមកវិបស់ខ្លួន ភាគីចុះកិច្ចព្រមព្រៀងត្រូវអនុវត្តអោយស្របតាមបទបញ្ញត្តិសន្តិសុខអាកាសចរ ដែលកំណត់ដោយអង្គការអាកាសចរស៊ីវិលអន្តរជាតិ និង មានបញ្ជាក់ជាឧបសម្ព័ន្ធចំពោះអនុសញ្ញានេះ ភាគីចុះកិច្ចព្រមព្រៀងត្រូវតម្រូវថា អ្នកធ្វើប្រតិបត្តិការអាកាសយាន ដែលបានចុះបញ្ជីនៅក្នុងទឹកដីរបស់ខ្លួន អ្នកធ្វើប្រតិបត្តិការអាកាសយាន ដែលមានស្នាក់ការពាណិជ្ជកម្មធំរបស់ខ្លួន ឬ និវេសនដ្ឋានអចិន្ត្រៃយ៍នៅក្នុងទឹកដីរបស់ខ្លួន និង អ្នកធ្វើប្រតិបត្តិការអាកាសយានដ្ឋាននៅក្នុងទឹកដីរបស់ខ្លួន ត្រូវអនុវត្តអោយស្របតាមបទបញ្ញត្តិសន្តិសុខអាកាសចរនេះ ។

៤. ភាគីចុះកិច្ចព្រមព្រៀងនីមួយៗ ត្រូវប្រកាន់ភ្ជាប់បទបញ្ញត្តិសន្តិសុខ ដែលតំរូវដោយភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀត សំរាប់ការធ្វើដំណើរចូលមក ការធ្វើដំណើរចេញទៅ និង ការស្ថិតនៅក្នុងទឹកដីរៀងៗខ្លួន ហើយត្រូវចាត់វិធានការសមស្រប ដើម្បីការពារអាកាសយាន និង ដើម្បីត្រួតពិនិត្យក្រុមអាកាសយានិក និង របស់របរយកតាមខ្លួន រួមទាំងទំនិញ និង គ្រឿងឧបភោគបរិភោគ អុន និង អំឡុងពេលផ្ទុកឡើង ឬ ដាក់ចុះ ។ ភាគីចុះកិច្ចព្រមព្រៀង នីមួយៗត្រូវផ្តល់តំលៃតបស្នងវិជ្ជមានផងដែរ ទៅតាមការស្នើសុំណាមួយពីភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀត ដើម្បីសុំ អោយចាត់វិធានការសន្តិសុខទប់ស្កាត់អំពើគំរាមកំហែងណាមួយ ។

៥. នៅពេលដែលឧបទ្ទវហេតុ ឬ ការគំរាមកំហែងនៃឧបទ្ទវហេតុ ក្នុងការចាប់យកអាកាសយានស៊ីវិលខុសច្បាប់ ឬ អំពើខុសច្បាប់ផ្សេងទៀត ប្រឆាំងនឹងសុវត្ថិភាពក្រុមអាកាសយានិក អាកាសយាន អាកាសយានដ្ឋាន ឬ ឧបករណ៍បញ្ជាចរាចរដែនអាកាសកើតឡើង ភាគីចុះកិច្ចព្រមព្រៀងត្រូវសុំអោយមានការចាត់វិធានការសមស្របតាមរយៈការប្រាស្រ័យទាក់ទងក្នុងគោលបំណងបញ្ចប់នូវឧបទ្ទវហេតុ ឬ ការគំរាមកំហែងសុវត្ថិភាពនេះអោយបានឆាប់ និង មានសុវត្ថិភាព ។

៦. នៅពេលដែលភាគីចុះកិច្ចព្រមព្រៀងមួយមានមូលហេតុសមហេតុផល ដែលជឿថា ភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀតបានអនុវត្តឃ្លាតចាកពីខ្លឹមសារសន្តិសុខអាកាសចរនៃមាត្រានេះ អាជ្ញាធរអាកាសចរនៃភាគីចុះកិច្ចព្រមព្រៀងនោះ អាចស្នើសុំពិគ្រោះយោបល់ជាបន្ទាន់ ជាមួយអាជ្ញាធរអាកាសចរនៃភាគីចុះ

បកប្រែត្រឹមផ្លូវការ

គិតពីថ្ងៃស្នើសុំនេះ ត្រូវបង្កើតបានជាមូលហេតុ ដើម្បីដកហូត រំលាយ ផ្អាក ដាក់លក្ខខ័ណ្ឌ ឬ ដាក់កំរិតទៅលើច្បាប់អនុញ្ញាតប្រតិបត្តិការ និង ច្បាប់អនុញ្ញាតបច្ចេកទេស របស់ក្រុមហ៊ុនអាកាសចរនៃភាគីចុះកិច្ចព្រមព្រៀងនោះ។ នៅពេលដែលមានភាពបន្ទាន់ ភាគីចុះកិច្ចព្រមព្រៀងមួយអាចចាត់វិធានការបណ្តោះអាសន្នមុនថ្ងៃផុតកំណត់ ១៥ ថ្ងៃ។

៧. ភាគីចុះកិច្ចព្រមព្រៀងនីមួយៗតម្រូវអោយក្រុមហ៊ុនអាកាសចរនៃភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀត ផ្តល់សេវាកម្មចំពោះភាគីចុះកិច្ចព្រមព្រៀង ដើម្បីជូនកម្មវិធីសន្តិសុខអ្នកធ្វើប្រតិបត្តិការ ដែលត្រូវបានឯកភាពដោយអាជ្ញាធរអាកាសចរនៃភាគីចុះកិច្ចព្រមព្រៀង របស់ក្រុមហ៊ុនអាកាសចរ ដើម្បីទទួលយក។

មាត្រា ៧
អត្រាតម្លៃ

១. តម្លៃដែលត្រូវបានដាក់អោយប្រើប្រាស់ ដោយក្រុមហ៊ុនអាកាសចរមួយ ឬ ច្រើន ដែលបានចាត់តាំងដោយភាគីចុះកិច្ចព្រមព្រៀងមួយសំរាប់បំរើសេវាកម្មផ្លូវអាកាស ដែលគ្របដណ្តប់ ឬ ស្ថិតនៅក្នុងកិច្ចព្រមព្រៀងនេះ តម្លៃទាំងនោះត្រូវបានបង្កើត និង រៀបចំអោយស្ថិតក្នុងកំរិតសមស្របមួយ ដែលយោងដល់ការចង់ប្រាក់តាម វិក័យប័ត្ររួម និង ប្រយោជន៍អ្នកប្រើប្រាស់ ប្រាក់សំរាប់ប្រតិបត្តិការ ប្រភេទលក្ខណៈសេវាកម្ម ប្រាក់ចំណេញសមស្រប តម្លៃប្រើប្រាស់របស់ក្រុមហ៊ុនអាកាសចរផ្សេងទៀត និង តំលៃក្នុងការសិក្សាទីផ្សារ ដើម្បីផ្តល់សេវាកម្ម។

២. តម្លៃដែលត្រូវបានអនុវត្តដោយបណ្តាក្រុមហ៊ុនអាកាសចរ ដែលបានចាត់តាំង មិនត្រូវបានស្នើសុំអោយបំពេញទំរង់តាម ឬ មានការយល់ព្រមឯកភាពដោយភាគីចុះកិច្ចព្រមព្រៀងឡើយ។ ទោះជាយ៉ាងណាក៏ដោយ បើច្បាប់ជាតិនៃភាគីចុះកិច្ចព្រមព្រៀងនោះ បានតម្រូវ និង ស្នើសុំអោយមានការយល់ព្រមឯកភាពជាមុនទៅលើតម្លៃ ត្រូវធ្វើអោយបានសមស្របតាមនីតិវិធីច្បាប់នៃប្រទេសនោះ។

៣. គ្រប់ភាគីចុះកិច្ចព្រមព្រៀងនីមួយៗ ត្រូវផ្តល់នូវការយកចិត្តទុកដាក់ជាពិសេសទៅលើតម្លៃអនុវត្តដែលអាច នឹងត្រូវបានបដិសេធចោល ដោយមានការលេចចេញនូវការរើសអើងមិនសមហេតុផល តម្លៃខ្ពស់ហួសកំរិត ឬ មានការរារាំងពីសំណាក់អំណាចនៃភាគី ឬ ការច្នៃប្រឌិតតម្លៃអោយធ្លាក់ចុះទាបបំផុត តាមរយៈការជួយឧបត្ថម្ភ គាំទ្រដោយផ្ទាល់ ឬ មិនផ្ទាល់ពីរដ្ឋាភិបាល ឬ ការប្រឆាំងតបនឹងតម្លៃប្រើប្រាស់ក្នុងលក្ខណៈប្រកួតប្រជែង។

៤. គ្រប់ភាគីចុះកិច្ចព្រមព្រៀងនីមួយៗ ត្រូវធានាអោយបានច្បាស់ ចំពោះក្រុមហ៊ុនអាកាសចរមួយ ឬច្រើន ដែលបានចាត់តាំង ត្រូវផ្តល់សេវាកម្មជាសាធារណៈទូទៅជាមួយនឹងព័ត៌មានត្រឹមត្រូវអំពីអត្រា និងតម្លៃសំបុត្រផ្ទរអាកាស ដែលមានភ្ជាប់ទៅនឹងលក្ខខ័ណ្ឌផ្សព្វផ្សាយទីផ្សារដល់សាធារណៈជន អំពីអត្រាតម្លៃរបស់ក្រុមហ៊ុនអាកាសចរដែលបានចាត់តាំង។

មាត្រា ៨

ប្រតិបត្តិការអាកាសយានជួល

១. នៅពេលក្រុមហ៊ុនអាកាសចរដែលបានចាត់តាំង ស្នើសុំប្រើប្រាស់អាកាសយានក្រៅពីអាកាសយានកម្មសិទ្ធិរបស់ខ្លួនផ្ទាល់ ដើម្បីបំរើសេវាកម្ម ដឹកជញ្ជូនទំនិញតាមផ្លូវអាកាសអន្តរជាតិ ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ កិច្ចប្រតិបត្តិការនេះត្រូវអនុវត្តឡើងបានលុះត្រាតែគោរពតាមលក្ខខ័ណ្ឌដូចតទៅ៖

ក. កិច្ចព្រមព្រៀងនេះ នឹងមិនមានតម្លៃស្មើការអនុញ្ញាតក្រុមហ៊ុនអាកាសចរអ្នកជួលនៃភាគីទី ៣ ដើម្បីឈានទៅអនុវត្តសិទ្ធិធ្វើចរាចរមិនអាចអនុវត្តបានចំពោះក្រុមហ៊ុនអាកាសចរនោះ។

ខ. ផលចំណេញហិរញ្ញវត្ថុដែលទទួលបានដោយក្រុមហ៊ុនអាកាសចរអ្នកជួលអាកាសយាន និងមិនផ្អែកលើផលចំណេញ ឬ ខាតនៃប្រតិបត្តិការរបស់ក្រុមហ៊ុនអាកាសចរពាក់ព័ន្ធ ដែលបានចាត់តាំងនោះ និង

គ. ការទទួលខុសត្រូវសុវត្ថិភាពហោះហើរបន្ត និង ភាពត្រឹមត្រូវនៃប្រតិបត្តិការ និង ស្តង់ដាគ្រប់គ្រងអាកាសយានជួល ដែលធ្វើប្រតិបត្តិការដោយក្រុមហ៊ុនអាកាសចរដែលបានចាត់តាំងដោយភាគីចុះកិច្ចព្រមព្រៀងមួយ និង ត្រូវបង្កើតឡើងស្របតាមអនុសញ្ញា។

២. ក្រុមហ៊ុនអាកាសចរដែលបានចាត់តាំងមិនត្រូវហាមឃាត់ពីការធ្វើសេវាកម្ម ដែលប្រើប្រាស់អាកាសយានជួល លុះត្រាតែកិច្ចព្រមព្រៀងជួលអាកាសយានត្រូវបានធ្វើឡើងស្របនឹងលក្ខខ័ណ្ឌ ដែលមានកំណត់នៅក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ។

បកប្រែសម្រាប់ផ្តល់ភាព

មាត្រា ៩
សកម្មភាពពាណិជ្ជកម្ម

១. អនុលោមតាមច្បាប់ និង បទបញ្ញត្តិនៃភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀត ក្រុមហ៊ុនអាកាសចរ ដែលបានចាត់តាំងនៃភាគីចុះកិច្ចព្រមព្រៀងមួយ មានសិទ្ធិ៖

ក. ពាក់ព័ន្ធការចូលមក ការស្នាក់នៅ ការផ្តល់ការងារ ដើម្បីនាំចូល និង គ្រប់គ្រងនៅក្នុងទឹកដីនៃភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀត នូវបុគ្គលិកគ្រប់គ្រង និង បុគ្គលិកជំនាញផ្សេងៗទៀត សំភារៈការិយាល័យ និង សំភារៈពាក់ព័ន្ធផ្សេងៗទៀត និង សំភារៈផ្សព្វផ្សាយពាណិជ្ជកម្ម សំរាប់អោយប្រតិបត្តិការសេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវអាកាសអន្តរជាតិ។

ខ. បង្កើតការិយាល័យនៅក្នុងទឹកដីភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀត ក្នុងគោលបំណងធ្វើសេវាកម្មតាមផ្លូវអាកាស ផ្សព្វផ្សាយពាណិជ្ជកម្មសេវាកម្មផ្លូវអាកាស និង ការលក់សេវាកម្មផ្លូវអាកាស។

គ. រៀបចំចាត់ចែងការលក់សេវាកម្មផ្លូវអាកាសនៅក្នុងទឹកដីនៃភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀតដោយខ្លួនឯងផ្ទាល់ និង តាមរយៈភ្នាក់ងាររបស់ខ្លួន ដើម្បីបំរើសេវាកម្មផ្លូវអាកាសនេះ និង បុគ្គលណាម្នាក់ មានសិទ្ធិដោយសេរី ដើម្បីទិញសេវាកម្មនេះដោយសេរីជារូបិយប័ណ្ណក្នុងស្រុកនៃទឹកដីនោះ ឬ ផ្អែកលើច្បាប់ និង បទបញ្ញត្តិជាតិ អាចប្តូររូបិយប័ណ្ណនៃប្រទេសផ្សេងៗទៀតដោយសេរី។

ឃ. បង្វែរ និង ផ្ទេរទៅកាន់ទឹកដីនៃសាជីវកម្មរបស់ខ្លួននូវផលចំណេញក្នុងស្រុកដែលសល់ពីការចំណាយតាមតំរូវការ។ ការបង្វែរ និង ផ្ទេរត្រូវបានអនុញ្ញាតដោយគ្មានការរឹតបន្តឹង ឬ យកពន្ធ ចំពោះអត្រាប្តូរប្រាក់ ដែលកំពុងអនុវត្តធុរៈកិច្ចបច្ចុប្បន្ន និង ការផ្ទេរអាស្រ័យលើកាលបរិច្ឆេទ ដែលក្រុមហ៊ុនដឹកជញ្ជូនធ្វើការអនុវត្តន៍ដំបូងសំរាប់ការផ្ទេរនេះ។ ការបង្វែរ និង ផ្ទេរនេះ ត្រូវបានធ្វើឡើងស្របតាមបទបញ្ញត្តិប្តូររូបិយប័ណ្ណបរទេសនៃភាគីចុះកិច្ចព្រមព្រៀងពាក់ព័ន្ធ។

ង. ចំណាយក្នុងស្រុករួមមាន ទិញប្រេងឥន្ធនៈនៅក្នុងទឹកដីនៃភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀតជារូបិយប័ណ្ណក្នុងស្រុក។ ក្រុមហ៊ុនអាកាសចរនៃភាគីចុះកិច្ចព្រមព្រៀងនីមួយៗអាច

បកប្រែត្រាផ្ទះគារ

ធ្វើការចំណាយនេះ ដោយខ្លួនឯងផ្ទាល់នៅក្នុងទឹកដីនៃភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀត តាមរយៈរូបិយប័ណ្ណប្តូរស្របតាមបទបញ្ជាត្តិរូបិយប័ណ្ណក្នុងស្រុក។

២. ក្នុងប្រតិបត្តិការ ឬ ការអនុវត្តន៍សេវាកម្ម ដែលអនុញ្ញាតនៅលើផ្លូវដែលបានឯកភាពគ្នា ក្រុមហ៊ុនអាកាសចរ ដែលបានចាត់តាំងអាចធ្វើកិច្ចព្រមព្រៀងទីផ្សារប្រតិបត្តិការ ដោយផ្អែកលើច្បាប់ និង បទបញ្ជាត្តិជាតិ ដែលអាចបញ្ចូល ប៉ុន្តែមិនត្រូវបានកំរិតចំពោះការរកស៊ីជាដៃគូ ការរកស៊ីរួមគ្នាដោយកំណត់បែងចែកចំនួនកៅជាមួយ៖

ក. ក្រុមហ៊ុនអាកាសចរមួយ ឬ ច្រើននៃភាគីចុះកិច្ចព្រមព្រៀងដូចគ្នា

ខ. ក្រុមហ៊ុនអាកាសចរមួយ ឬ ច្រើននៃភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀត និង

គ. ក្រុមហ៊ុនដឹកជញ្ជូនតាមផ្លូវគោក និង ផ្លូវទឹក នៃភាគីចុះកិច្ចព្រមព្រៀងណាមួយ

លុះត្រាតែ ភាគីនៅក្នុងកិច្ចព្រមព្រៀងនេះ មានសិទ្ធិគ្រប់គ្រាន់ និង បំពេញបានលក្ខខ័ណ្ឌចំពោះកិច្ចព្រមព្រៀងនេះ។

៣. ផ្អែកលើច្បាប់ជាតិ បទបញ្ជា បទបញ្ជាត្តិ នៃភាគីចុះកិច្ចព្រមព្រៀងនីមួយៗ ក្រុមហ៊ុនអាកាសចរដែលបានចាត់តាំងណាមួយ និង ក្រុមហ៊ុនបំរើសេវាកម្មដឹកជញ្ជូនទំនិញដោយប្រយោល នៃភាគីចុះកិច្ចព្រមព្រៀងនីមួយៗ ត្រូវបានអនុញ្ញាតដោយមិនរឹតបន្តឹង ដើម្បីធ្វើការដឹកជញ្ជូនទំនិញតាមផ្លូវគោក និង ផ្លូវទឹក ជាប់ពាក់ព័ន្ធសេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវអាកាសអន្តរជាតិ ទៅ ឬ មក ចំណុចណាមួយនៅក្នុង ឬ នៅក្រៅទឹកដីនៃភាគីចុះកិច្ចព្រមព្រៀង រួមមានការដឹកជញ្ជូនទៅ និង មក អាកាសយានដ្ឋានដែលមានបំពាក់ឧបករណ៍ត្រួតពិនិត្យរបស់អង្គភាពគយទាំងអស់ និង រួមមានទឹកន្លែងដែលអាចអនុវត្តបាន សិទ្ធិដឹកជញ្ជូនទំនិញចូលក្រោមច្បាប់ និង បទបញ្ជាត្តិដែលកំពុងអនុវត្ត។ ទោះបីទំនិញនេះ ត្រូវបានដឹកជញ្ជូនតាមផ្លូវទឹក និង ផ្លូវគោក ឬ ផ្លូវអាកាស ត្រូវឆ្លងកាត់ដំណើរការ និង ឧបករណ៍ និង ដំណើរការត្រួតពិនិត្យគយអាកាសយានដ្ឋាន។ ផ្អែកលើច្បាប់ជាតិ បទបញ្ជា បទបញ្ជាត្តិ នៃភាគីចុះកិច្ចព្រមព្រៀងនីមួយៗ ក្រុមហ៊ុនអាកាសចរដែលបានចាត់តាំងអាចជ្រើសរើសអោយអនុវត្តការដឹកជញ្ជូនទំនិញតាមផ្លូវគោក និង ផ្លូវទឹក ដោយខ្លួនឯងផ្ទាល់ ឬ ផ្តល់សេវាកម្មដឹកជញ្ជូននេះតាមរយៈកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនដឹកជញ្ជូនផ្លូវគោក និង ផ្លូវទឹកផ្សេងទៀត រួមមាន ការដឹកជញ្ជូនផ្លូវគោក និង ផ្លូវទឹក ដែលប្រតិបត្តិការដោយក្រុមហ៊ុនអាកាសចរផ្សេងទៀត និង ក្រុមហ៊ុនដឹកជញ្ជូនទំនិញតាមផ្លូវអាកាសដោយប្រយោល។ សេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវគោក និង ផ្លូវទឹកទាំងនេះ អាចត្រូវបានធ្វើឡើងដោយឯកឯងតាមរយៈតំលៃដឹកជញ្ជូនតាមផ្លូវគោក

ផ្លូវទឹក និង ផ្លូវអាកាសរួមបញ្ចូលគ្នា លុះត្រាតែយានដឹកជញ្ជូនទំនិញនេះ មកចំទិសដៅជាប់ពាក់ព័ន្ធនឹងការដឹកជញ្ជូនទំនិញនេះ ។

មាត្រា ១០
ការផ្លាស់ប្តូរអាកាសយាន

១. ក្រុមហ៊ុនអាកាសចរដែលបានចាត់តាំងនីមួយៗ អាចធ្វើការផ្លាស់ប្តូរអាកាសយានណាមួយ ឬ គ្រប់ការហោះហើរទាំងអស់ ចំពោះសេវាកម្មដែលបានឯកភាព និង តាមជំរើសរបស់ខ្លួននៅក្នុងទឹកដីនៃភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀត ឬ តាមចំណុចណាមួយ នៃផ្លូវហោះហើរដែលបានបញ្ជាក់ លុះត្រាតែ៖-

ក. អាកាសយានដែលប្រើនៅលើផ្លូវហោះហើរ ដែលផ្លាស់ប្តូរអាកាសយានត្រូវបានកំណត់កម្មវិធីហោះហើរ ព្រមគ្នាជាមួយនឹងអាកាសយានចេញដំណើរ ឬ អាកាសយានមកដល់ទៅតាមករណីដែលមាន និង

ខ. ក្នុងករណីផ្លាស់ប្តូរអាកាសយាននៅក្នុងទឹកដីភាគីដទៃទៀត និង នៅពេលដែលអាកាសយានច្រើនជាងមួយគ្រឿង ត្រូវបានអនុញ្ញាតអោយធ្វើប្រតិបត្តិការនៅលើចំណុចដែលផ្លាស់ប្តូរមិនមានអាកាសយានច្រើនជាងមួយគ្រឿង ដែលមានទំហំស្មើគ្នា និង មិនមានទំហំធំជាងអាកាសយាន ដែលប្រើនៅក្នុងតំបន់សិទ្ធិចរាចរទី ៣ និង ទី ៤ លុះត្រាតែចំណុះសរុប ដែលបានអនុញ្ញាតនៃអាកាសយានជើងហោះហើរ នៅពេលសរុបបញ្ចូលគ្នាមិនលើសចំណុះសរុបនៃអាកាសយាន ដែលមកដល់នៅឯចំណុចដែលធ្វើការផ្លាស់ប្តូរ ។

២. ក្នុងបំណងនៅពេលធ្វើការផ្លាស់ប្តូរប្រតិបត្តិការអាកាសយាន ក្រុមហ៊ុនអាកាសចរមួយ ដែលបានចាត់តាំងអាចប្រើប្រាស់ឧបករណ៍ផ្ទាល់ខ្លួន អាស្រ័យទៅលើច្បាប់ បទបញ្ជា និង បទបញ្ជត្តិជាតិ ឧបករណ៍ដែលត្រូវជួល ហើយអាចប្រតិបត្តិការតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មជាមួយក្រុមហ៊ុនអាកាសចរដទៃទៀត ។

៣. ក្រុមហ៊ុនអាកាសចរមួយ ដែលបានចាត់តាំង អាចប្រើប្រាស់លេខហោះហើរដើម ឬ ផ្សេងសំរាប់តំបន់នៃការប្រតិបត្តិការផ្លាស់ប្តូរអាកាសយានរបស់ខ្លួន ។

មាត្រា ១១
តម្លៃប្រើប្រាស់ឧបករណ៍

១. ភ្នានភាគីចុះកិច្ចព្រមព្រៀងណាមួយត្រូវដាក់ ឬ អនុញ្ញាតអោយកំណត់តម្លៃប្រើប្រាស់ឧបករណ៍ទៅលើក្រុមហ៊ុនអាកាសចរ ដែលបានចាត់តាំងនៃភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀត ខ្ពស់ជាងតម្លៃដែលត្រូវបានកំណត់យកទៅលើក្រុមហ៊ុនអាកាសចររបស់ខ្លួនផ្ទាល់ ដែលធ្វើប្រតិបត្តិការសេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវអាកាសអន្តរជាតិដូចគ្នានេះដែរ ។

២. ភាគីចុះកិច្ចព្រមព្រៀងនីមួយៗត្រូវជំរុញលើកទឹកចិត្តអោយមានការពិគ្រោះយោបល់ ស្តីពីតម្លៃប្រើប្រាស់ឧបករណ៍ រវាងអាជ្ញាធរមានសមត្ថកិច្ចកំណត់តម្លៃ និង ក្រុមហ៊ុនអាកាសចរដែលធ្វើ និង ប្រើប្រាស់សេវាកម្ម និង ឧបករណ៍ដែលផ្តល់ដោយអាជ្ញាធរកំណត់តម្លៃទាំងនោះ ដែលអនុវត្តតាមរយៈអង្គការតំណាងរបស់ក្រុមហ៊ុនអាកាសចរ។ សេចក្តីជូនដំណឹងសមហេតុផល ស្តីពីការឯកភាពចំពោះការប្តូរតម្លៃប្រើប្រាស់ឧបករណ៍ណាមួយ គួរត្រូវជូនដំណឹងទៅអ្នកប្រើប្រាស់ ដើម្បីអោយពួកគេអាចបញ្ចេញយោបល់មុននឹងការផ្លាស់ប្តូរត្រូវបានធ្វើឡើង។ ភាគីចុះកិច្ចព្រមព្រៀងនីមួយៗត្រូវជំរុញអាជ្ញាធរមានសមត្ថកិច្ចកំណត់តម្លៃរបស់ខ្លួន និង អ្នកប្រើប្រាស់អោយផ្លាស់ប្តូរព័ត៌មានសមរម្យ ដែលពាក់ព័ន្ធនឹងតម្លៃប្រើប្រាស់ឧបករណ៍នោះ ។

មាត្រា ១២
ពន្ធគយ

១. ភាគីចុះកិច្ចព្រមព្រៀងនីមួយៗ ដោយឈរលើគោលការណ៍បងិការ ត្រូវអោយក្រុមហ៊ុនអាកាសចរដែលបានចាត់តាំងនៃភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀតណាមួយ អោយរួចពីពន្ធគយនាំចូល ពន្ធអាករ ថ្លៃត្រួតពិនិត្យ និង តម្លៃ ពន្ធជាតិជាអតិបរមា ដែលអាចធ្វើទៅបាន ចំពោះអាកាសយាន ប្រេងឥន្ធនៈ ឧបករណ៍បំរើផ្ទៃដី ប្រេងរំអិល ឧបករណ៍បច្ចេកទេសសំរាប់ប្រើប្រាស់ គ្រឿងបន្លាស់ រួមមានម៉ាស៊ីន ឧបករណ៍បំរើអាកាសយានជាប្រចាំ គ្រឿង ឧបភោគបរិភោគ និង របស់របរផ្សេងៗទៀត ដូចជា បញ្ជីរាយមុខទំនិញ សំភារៈដែលមានសញ្ញាសំគាល់ក្រុមហ៊ុន និង សំភារៈដែលគេចោះពុម្ពផ្សព្វផ្សាយបំរើសាធារណៈជន ដោយឥតគិតថ្លៃរបស់ក្រុមហ៊ុនអាកាសចរ ដែលបានចាត់តាំងនោះ ក្នុងបំណងដើម្បីប្រើប្រាស់ ឬ ត្រូវបានប្រើប្រាស់ទៅលើប្រតិបត្តិការ ឬ បំរើសេវាកម្មអោយអាកាសយានរបស់ក្រុមហ៊ុនអាកាសចរដែលបានចាត់តាំងនៃភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀត ដែលធ្វើប្រតិបត្តិការសេវាកម្ម ដែលបានឯកភាពគ្នា ។

បកប្រែក្រៅផ្លូវការ

២. ការលើកលែងពន្ធ ដែលមានចែងនៅក្នុងមាត្រានេះ ត្រូវអនុវត្តទៅលើមុខទំនិញដែលមានចែងនៅក្នុងកថាខ័ណ្ឌ ១៖

ក. នាំចូលមកក្នុងទឹកដីនៃភាគីចុះកិច្ចព្រមព្រៀង ឬ ក្នុងនាមក្រុមហ៊ុនអាកាសចរ ដែលបានចាត់តាំងរបស់ភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀត។

ខ. រក្សាទុកនៅលើអាកាសយានរបស់ក្រុមហ៊ុនអាកាសចរ ដែលបានចាត់តាំងនៃភាគីចុះកិច្ចព្រមព្រៀងមួយនៅពេលមកដល់ក្នុង ឬ ចាកចេញពីទឹកដីនៃភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀតឬ

គ. យកតាមអាកាសយាន របស់ក្រុមហ៊ុនអាកាសចរដែលបានចាត់តាំងនៃភាគីចុះកិច្ចព្រមព្រៀងមួយ នៅក្នុងទឹកដីនៃភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀត ហើយក្នុងគោលបំណងប្រើប្រាស់ធ្វើប្រតិបត្តិការសេវាកម្មដែលបានឯកភាពគ្នា។

មុខទំនិញនេះត្រូវបានប្រើប្រាស់ ឬ មិនប្រើប្រាស់ទាំងស្រុងនៅក្នុងទឹកដីនៃភាគីចុះកិច្ចព្រមព្រៀងដែលអោយរួចពន្ធ លុះត្រាតែ កម្មសិទ្ធិនៃមុខទំនិញនេះ មិនត្រូវបានផ្ទេរនៅក្នុងទឹកដីនៃភាគីចុះកិច្ចព្រមព្រៀងនោះ។

៣. ឧបករណ៍ដាក់តាមអាកាសយានជាប្រចាំ រួមទាំងសំភារៈ និង ឧបករណ៍ផ្គត់ផ្គង់ ជាធម្មតាត្រូវបានគេរក្សាទុកនៅលើអាកាសយាននៃក្រុមហ៊ុនអាកាសចរ ដែលបានចាត់តាំងមួយ របស់ភាគីចុះកិច្ចព្រមព្រៀងណាមួយក្នុងចំណោមភាគីចុះកិច្ចព្រមព្រៀងទាំងពីរ អាចត្រូវបានដាក់ចុះ នៅក្នុងទឹកដីនៃភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀត លុះត្រាតែ មានការឯកភាពពីអាជ្ញាធរគយនៃទឹកដីនោះ។ ក្នុងករណីនេះ មុខទំនិញទាំងនេះត្រូវដាក់នៅក្រោមការត្រួតពិនិត្យរបស់អាជ្ញាធរគយ រហូតដល់ពេលដែលមុខទំនិញទាំងនេះត្រូវបាននាំចេញទៅវិញ ឬ ពុំដូច្នោះទេ ត្រូវបំពេញតាមបទបញ្ញត្តិគយ។

៤. ការលើកលែងត្រូវបានបញ្ជាក់នៅក្នុងមាត្រានេះ នឹងត្រូវអាចអនុវត្តបាន ប្រសិនបើក្រុមហ៊ុនអាកាសចរ ដែលបានចាត់តាំងនៃភាគីចុះកិច្ចព្រមព្រៀងមួយបានធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុនអាកាសចរដែលបានចាត់តាំងផ្សេងទៀត ដែលអនុវត្តការលើកលែងនេះ ពីភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀត ឬ ភាគីចុះកិច្ចព្រមព្រៀងច្រើនផ្សេងទៀត ចំពោះប្រាក់កម្ចី ឬ ការផ្ទេរនៅក្នុងទឹកដីនៃភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀត ឬ ភាគីចុះកិច្ចព្រមព្រៀងច្រើនផ្សេងទៀត ទៅលើមុខទំនិញ ដែលមានចែងនៅក្នុងកថាខ័ណ្ឌ ១ នៃ

បកប្រែក្រៅផ្លូវការ

មាត្រា ១៣
ការប្រកួតប្រជែងស្មើភាព

ភាគីចុះកិច្ចព្រមព្រៀងនីមួយៗឯកភាពគ្នា៖

ក. ក្រុមហ៊ុនអាកាសចរដែលបានចាត់តាំងនីមួយៗមានឱកាសស្មើភាព និង សមភាពគ្នា ដើម្បីប្រកួតប្រជែងសេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវអាកាសអន្តរជាតិដែលគ្របដណ្តប់ដោយកិច្ចព្រមព្រៀងនេះ។

ខ. ដើម្បីចាត់វិធានការបញ្ចប់រាល់ទំរង់ហើសអើងទាំងអស់ ឬក៏ការអនុវត្តន៍ប្រកួតប្រជែង ដោយជំទាស់របស់ភាគីចុះកិច្ចព្រមព្រៀងនោះ និង ក្រុមហ៊ុនអាកាសចរដែលបានចាត់តាំងរបស់ខ្លួន ដែលខ្លួនយល់ថាជះឥទ្ធិពលទៅលើ តួនាទីប្រកួតប្រជែងរបស់ក្រុមហ៊ុនអាកាសចរដែលបានចាត់តាំងនៃភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀតណាមួយ។

មាត្រា ១៤
កិច្ចការពារ

១. ភាគីចុះកិច្ចព្រមព្រៀងបានឯកភាពគ្នាថា ការអនុវត្តន៍របស់ក្រុមហ៊ុនអាកាសចរដូចខាងក្រោមនេះត្រូវចាត់ទុកថា ជាការអនុវត្តន៍ប្រឆាំងនឹងការប្រកួតប្រជែង ដែលតម្រូវអោយមានការត្រួតពិនិត្យច្បាស់លាស់៖

ក. ការយកតម្លៃសំបុត្រ និង ការយកអត្រាថ្លៃដឹកជញ្ជូន លើដំណាក់ផ្លូវនៅក្នុងកំរិតមួយដែលបូកបញ្ចូលតម្លៃចំណាយបន្ទាប់បន្សំ ចំពោះតម្លៃបំរើសេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវអាកាសអន្តរជាតិដែលពាក់ព័ន្ធ។

ខ. តម្លៃបន្ថែមទៅលើចំណុះដឹកជញ្ជូន ឬ ចំនួនជើងហោះហើរនៃសេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវអាកាសអន្តរជាតិដែលលើស។

គ. ការអនុវត្តន៍តម្លៃ ដែលធ្វើអោយក្រុមហ៊ុនអាកាសចរមាននិរន្តរភាព។

ឃ. ការអនុវត្តន៍តម្លៃ ដែលមានឥទ្ធិពលសេដ្ឋកិច្ចអវិជ្ជមានធ្ងន់ធ្ងរ ឬ ហេតុផលបង្កអោយមានការខូចខាតធ្ងន់ធ្ងរទៅលើក្រុមហ៊ុនអាកាសចរដទៃផ្សេងទៀត។

បកប្រែគ្រាដ្ឋចការ

ង. ការអនុវត្តន៍តម្លៃ ដែលមានចេតនា ឬ អាចមានឥទ្ធិពល ដែលអាចកើតមានឡើង ដើម្បីកំចាត់ក្រុមហ៊ុនអាកាសចរចេញពីទីផ្សារ និង

ច. ឥរិយាបថដែលបញ្ជាក់ការរំលោភនៃតួនាទីផ្តាច់មុខលើផ្លូវហោះហើរ ។

២. ប្រសិនបើអាជ្ញាធរអាកាសចរភាគីចុះកិច្ចព្រមព្រៀងមួយយល់ឃើញថា ការប្រតិបត្តិការសំដៅ ឬ ធ្វើឡើងដោយក្រុមហ៊ុនអាកាសចរ ដែលបានចាត់តាំងឡើងនៃភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀត ដែល បង្កើតបានជាឥរិយាបថប្រកួតប្រជែងមិនត្រឹមត្រូវ ស្របតាមបណ្តាចំណុចបញ្ជាក់នៅក្នុងកថាខ័ណ្ឌទី ១ ឬ ការរើសអើងណាមួយ តាមរយៈការឧបត្ថម្ភ ឬ ការឧបត្ថម្ភធនពីរដ្ឋមិនត្រឹមត្រូវ របស់ភាគីចុះកិច្ចព្រមព្រៀង ផ្សេងទៀត ភាគីចុះកិច្ចព្រមព្រៀងត្រូវស្នើសុំ ពិគ្រោះយោបល់ស្របតាមមាត្រា ១៧ (ការពិគ្រោះយោបល់ និង វិសោធនកម្ម) ដើម្បីដោះស្រាយបញ្ហា។ ប្រសិនបើការស្នើសុំនេះ ដែលត្រូវធ្វើឡើងដោយមានភ្ជាប់ សេចក្តីជូនដំណឹងពីហេតុផលនៃការស្នើសុំ ហើយកិច្ចពិគ្រោះយោបល់ ត្រូវចាប់ផ្តើមក្នុងរយៈពេល ១៥ ថ្ងៃ បន្ទាប់ពីទទួលបាននៃការស្នើសុំនេះ ។

៣. ប្រសិនបើភាគីចុះកិច្ចព្រមព្រៀងមិនឈានដល់ដំណោះស្រាយ នៃបញ្ហាតាមរយៈការពិគ្រោះ យោបល់ ភាគីចុះកិច្ចព្រមព្រៀងណាមួយ ក្នុងចំណោមភាគីចុះកិច្ចព្រមព្រៀងទាំងពីរ អាចប្រើប្រាស់យន្តការ ដោះស្រាយជំលោះក្រោមមាត្រា ១៨(ដំណោះស្រាយជំលោះ) ដើម្បីដោះស្រាយជំលោះ ។

៤. ការផ្តល់ជំនួយ ឬ ការឧបត្ថម្ភធនរបស់រដ្ឋ ត្រូវធ្វើឡើងក្នុងលក្ខណៈតម្លាភាព រវាង ភាគីចុះកិច្ចព្រម ព្រៀង ហើយមិនត្រូវធ្វើអោយប៉ះពាល់ដល់ការប្រកួតប្រជែង ក្នុងចំណោមក្រុមហ៊ុនអាកាសចរ ដែលបាន ចាត់តាំងនៃភាគីចុះកិច្ចព្រមព្រៀង។ ភាគីចុះកិច្ចព្រមព្រៀងពាក់ព័ន្ធត្រូវផ្តល់អោយភាគីចុះកិច្ចព្រមព្រៀង ផ្សេងទៀត តាមការស្នើសុំរបស់គេ នូវព័តិមានគ្រប់គ្រាន់ ស្តីពីការផ្តល់ជំនួយនេះ និង ការពិនិត្យឡើង វិញណាមួយ ឬ ការបន្ថែមនៃជំនួយនេះ ។ ព័តិមាននេះត្រូវធ្វើឡើងដោយភាពជឿជាក់ និង ស្មោះត្រង់បំផុត ។

មាត្រា ១៥

ការអនុវត្តន៍ច្បាប់ និង បទបញ្ញត្តិ

១. នៅខណៈពេលចូល ស្ថិតនៅក្នុង ឬ ចាកចេញ ពីទឹកដីនៃភាគីចុះកិច្ចសន្យាមួយ ច្បាប់ បទបញ្ញត្តិ និង បទបញ្ជា របស់ខ្លួនទាក់ទិនទៅនឹងការប្រតិបត្តិការ និង ការនាំផ្លូវនៃអាកាសយាន ត្រូវអនុវត្តអោយស្របតាម

២. នៅខណៈពេលចូលស្ថិតនៅក្នុង ឬ ក៏ចាកចេញពីទឹកដីនៃភាគីចុះកិច្ចព្រមព្រៀងមួយ ច្បាប់ បទបញ្ជត្តិ និង បទបញ្ជារបស់ខ្លួន ពាក់ព័ន្ធទៅនឹងការចូល ឬ ចេញដំណើរពីទឹកដីរបស់ខ្លួន នៃក្រុមអាកាសយានិក ឬ ទំនិញ នៅលើអាកាសយាន (រួមមាន បទបញ្ជត្តិទាក់ទិននឹងការចូល ត្រួតពិនិត្យ សន្តិសុខអាកាសចរ អន្តោរប្រវេសន៍ លិខិតឆ្លងដែន គយ និង ចត្តាឡីសក្ត ឬ ក្នុងចំពោះបទបញ្ជត្តិប្រៃសណីយ៍) នឹងត្រូវអនុវត្ត ដោយ ឬ ក្នុងនាមអាកាសយានិក ឬ ទំនិញរបស់ក្រុមហ៊ុនអាកាសចរនៃភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀត ។

៣. ទំនិញស្ថិតនៅក្នុងការបន្តជើងតាមរយៈទឹកដីនៃភាគីចុះកិច្ចព្រមព្រៀងណាមួយ និង មិនចេញដំណើរ ពីតំបន់ នៃអាកាសយានដ្ឋានដែលបានបំរុងទុកសំរាប់គោលបំណងមិនទទួលការលើកលែងការត្រួតពិនិត្យ ណាមួយ ចំពោះហេតុផលណាមួយ នៃសន្តិសុខអាកាសចរ ត្រួតពិនិត្យជាតិណាកូទិក ការការពារនៃការចូល ដែលខុសច្បាប់ ឬ ស្ថិតនៅក្នុងកាលៈទេសៈពិសេស ។

មាត្រា ១៦

ស្ថិតិ

អាជ្ញាធរអាកាសចរនៃភាគីចុះកិច្ចព្រមព្រៀងនីមួយៗត្រូវផ្តល់ស្ថិតិដល់អាជ្ញាធរអាកាសចរ នៃភាគី ចុះកិច្ចព្រមព្រៀងផ្សេងទៀត នូវស្ថិតិតាមកាលកំណត់ ឬ ក៏ព័ត៌មានប្រហាក់ប្រហែលផ្សេងៗទៀត ពាក់ព័ន្ធទៅនឹងចរាចរដឹកជញ្ជូន ស្តីពីសេវាកម្មដែលបានឯកភាពគ្នាទៅតាមការស្នើសុំ ។

មាត្រា ១៧

ការពិគ្រោះយោបល់ និង ការធ្វើវិសោធនកម្ម

១. អាជ្ញាធរអាកាសចរនៃភាគីចុះកិច្ចព្រមព្រៀង នឹងត្រូវពិគ្រោះយោបល់ ក្នុងចំណោមភាគីចុះកិច្ចព្រម ព្រៀងផ្សេងទៀត នៅពេលណាមួយ ដើម្បីធានាការអនុវត្តន៍អោយស្របតាមខ្លឹមសារនៃកិច្ចព្រមព្រៀង នេះ។ ប្រសិនបើមានការឯកភាពគ្នា កិច្ចពិគ្រោះយោបល់នេះ ត្រូវចាប់ផ្តើមនៅថ្ងៃបរិច្ឆេទ ដែលឆាប់បំផុត ដែលអាចធ្វើទៅបាន ប៉ុន្តែមិនអោយយឺតជាង ៦០ ថ្ងៃ គិតពីថ្ងៃដែលភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀតបាន ទទួលសំណើសុំជាលាយលក្ខណ៍អក្សរតាមរយៈកំណត់ទូត ឬ តាមរយៈទំនាក់ទំនងដទៃទៀត រួមមានការ ពន្យល់ពីបញ្ហាដែលនឹងត្រូវលើកឡើង។ នៅពេលដែលកាលបរិច្ឆេទសំរាប់កិច្ចពិគ្រោះយោបល់ត្រូវបាន ឯកភាពគ្នា ភាគីចុះកិច្ចព្រមព្រៀង ដែលស្នើសុំត្រូវជូនដំណឹងដល់គ្រប់ភាគីចុះកិច្ចព្រមព្រៀងផ្សេងទៀត

ចូលរួមនៅពេលដែលកិច្ចពិគ្រោះយោបល់ត្រូវបានបញ្ចប់ ភាគីចុះកិច្ចព្រមព្រៀងទាំងអស់ត្រូវបាន ជូនដំណឹងអំពីលទ្ធផល ព្រមទាំងអ្នកទទួលដំកល់ទុកឯកសារផងដែរ ។

២. ប្រសិនបើភាគីចុះកិច្ចព្រមព្រៀង ១ ភាគ ៣ យល់ថា មានបំណងធ្វើវិសោធនកម្មខ្លឹមសារណាមួយនៃកិច្ចព្រមព្រៀងនេះ ពួកគេមានសិទ្ធិ ដោយស្នើសុំទៅអគ្គលេខាធិការអាស៊ាន មិនអោយហួសពី ១២ ខែ ក្រោយពីកិច្ចព្រមព្រៀងនេះចូលជាធរមាន ដោយបង្កើតអោយមានកិច្ចប្រជុំនៃភាគីចុះកិច្ចព្រមព្រៀងទាំងអស់ ដើម្បីពិនិត្យពិចារណាវិសោធនកម្មណាមួយ ដែលពួកគេស្នើសុំធ្វើវិសោធនកម្មចំពោះកិច្ចព្រមព្រៀងនេះ។ វិសោធនកម្មនេះ ប្រសិនបើមានការឯកភាពក្នុងចំណោមភាគីចុះកិច្ចព្រមព្រៀង ហើយប្រសិនបើមានការចាំបាច់ក្រោយពីកិច្ចពិគ្រោះយោបល់ស្របតាមកថាខ័ណ្ឌនៃមាត្រានេះ ត្រូវចូលជាធរមាននៅពេលដែលភាគីចុះកិច្ចព្រមព្រៀងលើសពីពាក់កណ្តាល បានដំកល់ទុកលិខិតុបករណ៍ផ្តល់សច្ចាប័ននៃវិសោធនកម្មនេះរបស់ពួកគេ ។

៣. ប្រសិនបើមានការបញ្ចប់នៃអនុសញ្ញាពហុភាគីទូទៅណាមួយ ពាក់ព័ន្ធការដឹកជញ្ជូនចំនិញតាមផ្លូវអាកាសអន្តរជាតិ ដែលភាគីចុះកិច្ចព្រមព្រៀងទាំងអស់ជាសមាជិក កិច្ចព្រមព្រៀងនេះត្រូវបានកែតម្រូវដើម្បីអោយស្របតាមអនុសញ្ញានេះ ។

មាត្រា ១៨

ដំណោះស្រាយជម្លោះ

ខ្លឹមសារនៃពិធីសារអាស៊ាន ស្តីពីយន្តការដោះស្រាយជម្លោះអោយបានប្រសើរធ្វើនៅវៀងចន្ទន៍ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និង វិសោធនកម្មត្រូវអនុវត្តទៅលើជម្លោះដែលកើតឡើងក្រោមកិច្ចព្រមព្រៀងនេះ ។

មាត្រា ១៩

ទំនាក់ទំនងជាមួយកិច្ចព្រមព្រៀងផ្សេងទៀត

១. កិច្ចព្រមព្រៀងនេះ ឬ វិធានការណាមួយ ដែលត្រូវបានកំណត់ឡើងមិនត្រូវអោយប៉ះពាល់ដល់សិទ្ធិ និង កាតព្វកិច្ចនៃភាគីចុះកិច្ចព្រមព្រៀងស្ថិតក្រោមកិច្ចព្រមព្រៀង ដែលនៅជាធរមាន ឬ អនុសញ្ញាអន្តរជាតិ ដែលពួកគេជាភាគីចុះកិច្ចព្រមព្រៀង លើកលែងតែមានចែងនៅក្នុងកថាខ័ណ្ឌ ៣ នៃមាត្រានេះ ។

បកប្រែត្រឹមត្រូវ

២. គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ដែលនឹងត្រូវមិនមានសិទ្ធិរើសអើង ឬ ការអនុវត្តន៍សិទ្ធិទាំងនោះ ដោយភាគីចុះកិច្ចព្រមព្រៀងណាមួយ ស្ថិតនៅក្រោមបទបញ្ញត្តិនៃអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីច្បាប់សមុទ្រ ឆ្នាំ ១៩៨២ ជាពិសេសទាក់ទងសេរីភាពនៃដែនសមុទ្រ សិទ្ធិក្នុងការលើកលែងទោស សិទ្ធិឆ្លងកាត់ដែនសមុទ្រ ការឈប់សំចត នៃនាវា និង អាកាសយាន និង រួមទាំងការជួលនាវា ឬ អាកាសយាន របស់អង្គការសហប្រជាជាតិ។

៣. ប្រសិនបើមានភាពផ្ទុយគ្នា រវាងខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ និង ខ្លឹមសារនៃកិច្ចព្រមព្រៀងសេវាកម្មផ្លូវអាកាសទ្វេភាគី ឬ ពហុភាគី ដែលនៅជាធរមាន (រួមមាន វិសោធនកម្ម) ដែលភាគីចុះកិច្ចព្រមព្រៀងពីរ ឬ ច្រើនជារដ្ឋសមាជិកអាស៊ាន ឬ ដែលមិនត្រូវគ្របដណ្តប់ដោយកិច្ចព្រមព្រៀងនេះ ខ្លឹមសារដែលមានដាក់កំរិតតិច ឬ កំរិតសេរីច្រើន ឬ ដែលមិនគ្របដណ្តប់ដោយកិច្ចព្រមព្រៀងនេះ ត្រូវរក្សាទុករវាងភាគីចុះកិច្ចព្រមព្រៀងដែលបានពិភាក្សា។ ប្រសិនបើមានខ្លឹមពាក់ព័ន្ធភាពផ្ទុយគ្នា ដែលទាក់ទងនឹងសុវត្ថិភាព ឬ សន្តិសុខអាកាសចរ ខ្លឹមសារ ការដាក់បទបញ្ញត្តិមានកំរិតខ្ពស់ ឬ ខ្លាំងជាងស្តង់ដាសុវត្ថិភាព ឬ សន្តិសុខអាកាសចរ ត្រូវរក្សាទុកដើម្បីពង្រីកភាពប្រែប្រួលមិនសមហេតុផល។

មាត្រា ២០

អវសានបញ្ញត្តិ

១. កិច្ចព្រមព្រៀងនេះ ត្រូវបានដាក់ទុកដោយអ្នកទទួលដាក់ទុកឯកសារ ដែលត្រូវបង្កើតបានជាឯកសារច្បាប់ផ្លូវការ សំរាប់ភាគីចុះកិច្ចព្រមព្រៀងនីមួយៗ។

២. កិច្ចព្រមព្រៀងនេះ ត្រូវផ្តល់សច្ចាប័ន ឬ លិខិតទទួលស្គាល់ពីភាគីចុះកិច្ចព្រមព្រៀង។ លិខិតុបករណ៍ផ្តល់សច្ចាប័ន ឬ លិខិតទទួលស្គាល់ ត្រូវដាក់ទុកដោយអ្នកទទួលដាក់ទុកឯកសារ ហើយត្រូវជូនដំណឹងទៅភាគីចុះកិច្ចព្រមព្រៀងនីមួយៗ អំពីការដាក់ទុកឯកសារនេះ។

៣. កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមាន នៅកាលបរិច្ឆេទនៃការដាក់ឯកសារលិខិតុបករណ៍ផ្តល់សច្ចាប័ន ឬ លិខិតទទួលស្គាល់ទី ៣ ជាមួយអគ្គលេខាធិការដ្ឋានអាស៊ាន និង ត្រូវចូលជាធរមាននៅពេលដែលគ្រប់ភាគីចុះកិច្ចព្រមព្រៀងទាំងអស់បានផ្តល់សច្ចាប័ន ឬ លិខិតទទួលស្គាល់កិច្ចព្រមព្រៀងនេះ។

៤. ទោះបីមានចែងក្នុងកថាខ័ណ្ឌ ៣ នៃមាត្រានេះ ការអនុវត្តន៍ពិធីសារនៃកិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមាននៅពេលដែលការផ្តល់សច្ចាប័ន ឬ លិខិតទទួលស្គាល់ ដែលមានចែងនៅក្នុងអវសានបញ្ញត្តិនៃ

ពិធីសារអនុវត្តរៀងៗខ្លួន។ ខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តទៅលើពិធីសារអនុវត្ត ដែលចូលជាការមានក្នុងចំណោមភាគីចុះកិច្ចព្រមព្រៀងផ្តល់សច្ចាប័ន ឬលិខិតទទួលស្គាល់ ។

៥. អ្នកដាក់ទុកឯកសារត្រូវចាត់ទុកជាអ្នកចុះបញ្ជីការចាត់តាំងក្រុមហ៊ុនអាកាសចរកណ្តាល និងលិខិតអនុញ្ញាតប្រតិបត្តិការ ស្របតាមមាត្រា ៣ (ការចាត់តាំង និង ការអនុញ្ញាតក្រុមហ៊ុនអាកាសចរ) នៃកិច្ចព្រមព្រៀងនេះ ។

៦. នៅពេលដែលកិច្ចព្រមព្រៀងនេះចូលជាធរមានចំពោះគ្រប់ភាគីចុះកិច្ចព្រមព្រៀងទាំងអស់ អនុស្សរណៈយោគយល់អាស៊ាន ២០០២ ស្តីពីសេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវអាកាស ត្រូវទុកជានិរាករណ៍ ។

៧. អ្នកដាក់ទុកឯកសារត្រូវចុះបញ្ជីកិច្ចព្រមព្រៀងនេះជាបន្ទាន់ជាមួយអង្គការអាកាសចរស៊ីវិលអន្តរជាតិ នៅពេលដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន ។

ដើម្បីជាសក្ខីភាព ហត្ថលេខីដែលទទួលបានសិទ្ធិចុះហត្ថលេខាពីរដ្ឋាភិបាលរៀងៗខ្លួន បានចុះហត្ថលេខាកិច្ចព្រមព្រៀងពហុភាគីអាស៊ាន ស្តីពីសេរីភាវូបនីយកម្មពេញលេញនៃសេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវអាកាស ។

ធ្វើនៅ ម៉ានីឡា ប្រទេសហ្វីលីពីន ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៩ ជាអត្ថបទភាសាអង់គ្លេសប៉ុណ្ណោះ ។

ជួសមុខអោយរដ្ឋាភិបាល នៃប្រទេសប្រ៊ុយណេដារូសាឡាម

.....

ប៉េហ៊ីន ជាតូ អាប៊ូ ឋាកា អាប៉ុង

រដ្ឋមន្ត្រីក្រសួងគមនាគមន៍

ជួសមុខអោយរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

.....

ម៉ៅ ហាវណ្ណាល់

រដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

បកប្រែក្រៅផ្លូវការ

ជូនសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

.....

យ៉ាសម៉ាន់ ស៊ីយ៉ាហ្គី ដ្រាម៉ាល់

រដ្ឋមន្ត្រី ក្រសួងដឹកជញ្ជូន

ជូនសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

.....

សូមម៉ាត់ ថ្លូលសេដា

រដ្ឋមន្ត្រី ក្រសួងគមនាគមន៍ ដឹកជញ្ជូន ប្រៃសណីយ៍ និង សំណង់

ជូនសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

.....

ជាតុ ថ្រ្យ អុច ឆឺ ភាគ

រដ្ឋមន្ត្រី ក្រសួងដឹកជញ្ជូន

ជូនសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃសហភាពមីយ៉ាន់ម៉ា

.....

ឧត្តមសេនីយ៍ឯកឧត្តម ឆៀង ស្វៃ

រដ្ឋមន្ត្រី ក្រសួងដឹកជញ្ជូន

ជូនសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋហ្វីលីពីន

.....

ឧត្តមសេនីយ៍ លានដ្រូ អា. មេនដូហ្សា

រដ្ឋមន្ត្រី ក្រសួងដឹកជញ្ជូន និង ទូរគមនាគមន៍

បកប្រែត្រឹមត្រូវ

ជូសមុខអោយរដ្ឋាភិបាល នៃសាធារណរដ្ឋសិង្ហបុរី

.....

អ៊ែម៉ុង លីម

រដ្ឋមន្ត្រី ក្រសួងដឹកជញ្ជូន

ជូសមុខអោយរដ្ឋាភិបាល នៃព្រះរាជាណាចក្រថៃឡង់ដ៍

.....

សុផុន សារ៉ាម

រដ្ឋមន្ត្រី ក្រសួងដឹកជញ្ជូន

ជូសមុខអោយរដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម

.....

ហូ ថាំយ ខុង

រដ្ឋមន្ត្រី ក្រសួងដឹកជញ្ជូន

ASEAN MULTILATERAL AGREEMENT ON THE FULL LIBERALISATION OF AIR FREIGHT SERVICES

The Governments of Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, the Lao People's Democratic Republic (hereinafter referred as "Lao PDR"), Malaysia, the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand and the Socialist Republic of Viet Nam, Member States of the Association of Southeast Asian Nations (ASEAN) (hereinafter collectively referred to as "Contracting Parties" or individually as "Contracting Party")

RECALLING the Declaration of ASEAN Concord II (Bali Concord II) issued in Bali, Indonesia on 7 October 2003, pursuant to which ASEAN is committed to deepen and broaden its internal economic integration and linkages with the world economy to realise an ASEAN Economic Community;

AFFIRMING the policy agenda for progressive implementation of full liberalisation and integration of air services in ASEAN as laid down in the Action Plan for ASEAN Air Transport Integration and Liberalisation adopted at the Tenth (10^{th}) ASEAN Transport Ministers' (ATM) Meeting on 23 November 2004 in Phnom Penh, Cambodia;

RECALLING the Vientiane Action Programme adopted at the Tenth (10^{th}) ASEAN Summit on 29 November 2004 in Vientiane, Lao PDR, which calls for accelerating open sky arrangements and advancing liberalisation in air transport services, especially air freight services;

RECALLING also the decision of the Tenth (10th) ATM Meeting in Phnom Penh, Cambodia, on 23 November 2004 to adopt the Roadmap for Integration of Air Travel Sector and the Action Plan for ASEAN Air Transport Integration and Liberalisation 2005-2015, which provides strategic actions to further liberalise air services in ASEAN and promotes an enabling environment for a single and unified aviation market in ASEAN;

BEING committed to maintain, further develop and strengthen friendly relations and cooperation between and among their countries;

RECOGNISING that efficient and competitive international air freight services are important to develop trade, benefit consumers, and promote economic growth;

DESIRING to ensure the highest degree of safety and security in international air transport and reaffirm their grave concern about acts or threats against the security of aircraft, which jeopardise the safety of property, adversely affect the operation of air transportation, and undermine public confidence in the safety of civil aviation;

DESIRING to facilitate and enhance air freight services and their related activities, to complement the other transport facilitation and liberalisation efforts in ASEAN;

DESIRING to remove restrictions, on a gradual basis, so as to achieve greater flexibility and capacity in the operation of air freight services in ASEAN with a view to build a single unified aviation market of ASEAN by 2015;

BEING Parties to the Convention on International Civil Aviation, opened for signature at Chicago on 7 December 1944, and desiring to adhere to the principles and provisions of the aforesaid Convention; and

CERTIFIED COPY DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT asean

DESIRING to conclude a Multilateral Agreement on the Full Liberalisation of Air Freight Services

HAVE AGREED AS FOLLOWS:

ARTICLE 1
DEFINITIONS

